ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

# មតិស្វាគមន៍

ថ្លែងដោយ **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ
ក្នុងពិធីបើកកម្មវិធី «ទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ»
នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ
ថ្ងៃទីទី ១២ ខែធ្នូ ឆ្នាំ២០១៦

- សូមថ្វាយបង្គំ ព្រះថេរានុត្ថេរៈ គ្រប់ព្រះអង្គ ជាទីគោរពសក្ការៈ
- សូមគោរពសម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវ ជាទីគោរពដ៏ខ្ពង់ខ្ពស់
- ឯកឧត្តម លោកជំទាវ ជាប្រធាន អនុប្រធានគណៈកម្មាធិការ និងជាសមាជិកដ៏ឧត្តុង្គឧត្តមនៃព្រឹទ្ធសភា រដ្ឋសភា និងរាជរដ្ឋាភិបាល
- ឯកឧត្តម លោកជំទាវ តំណាងអង្គទូតនានា នៃបណ្តាប្រទេសជាមិត្ត
- ឯកឧត្តម លោកជំទាវ លោកឧកញ៉ា អ្នកឧកញ៉ា អស់លោក លោកស្រីភ្ញៀវជាតិ អន្តរជាតិ មន្ត្រីរាជការកងកម្លាំងគ្រប់ប្រភេទ
- សិស្សានុសិស្ស និយោជក កម្មករនិងបងប្អូនជនរួមជាតិ ជាទីគោរពស្នេហា

នៅក្នុងឱកាសនៃការប្រារព្ធទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ សម្រាប់ឆ្នាំ ២០១៦ ដ៏អធឹកអធមនេះ ក្នុងនាមនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងគណៈកម្មការរៀបចំកម្មវិធី នាងខ្ញុំសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះវត្តមានជាអធិបតីដ៏ខ្ពង់ខ្ពស់ របស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង លោកជំទាវ ព្រមទាំងការនិមន្ត និងអញ្ជើញចូលរួមពីព្រះថេរានុត្ថេរៈ គ្រប់ព្រះអង្គ ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវជាតិ អន្តរ ជាតិ ក្មួយៗយុវជន និស្សិត សិស្សានុសិស្សដ៏ច្រើនកុះករ

ដែលបានផ្តល់កិត្តិយស និងសម្តែងពីការយកចិត្តទុកដាក់ខ្ពស់ចំពោះ ការស្វែងយល់ និងចូលរួមប្តេជ្ញាចិត្ត ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។

ឱកាសជួបជុំដ៏មានអត្ថន័យនេះ មានគោលបំណងបញ្ជាក់ជូនជនរួមជាតិឲ្យបានជ្រាបថា រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបាន និងកំពុងយកចិត្តទុកដាក់យ៉ាងខ្លាំង ក្នុងការការពារប្រជាពលរដ្ឋ និងប្រទេសជាតិ ពីភាពរងគ្រោះទាំងឡាយ ដែលបង្កឡើងដោយឧក្រិដ្ឋជនជួញដូរមនុស្ស ដែលបានធ្វើអាជីវកម្ម ទារុណកម្ម និងកេងប្រវ័ញ្ចលើមនុស្សគ្រប់រូបភាព ។

អំពើជួញដូរមនុស្ស គឺជាឧក្រិដ្ឋកម្មដ៏រ៉ាំរ៉ៃមួយដែលកើតមាននៅគ្រប់បណ្តាប្រទេសក្នុងពិភពលោក ក្នុងចំណោមឧក្រិដ្ឋកម្មដទៃទៀត ដែលបាន និងកំពុងតែធ្វើឲ្យប៉ះពាល់ដល់សន្តិសុខមនុស្ស និងប្រទេសជាតិ ។ ប្រជាពលរដ្ឋមួយចំនួនធំ បាននិងកំពុងតែទទួលរងគ្រោះយ៉ាងធ្ងន់ធ្ងរពីអំពើជួញដូរមនុស្សតាមរយៈការកេងប្រវ័ញ្ចគ្រប់រូបភាព ការរំលោភបំពានលើសិទ្ធិសេរីភាព កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់មនុស្ស ដោយបានបំផ្លាញដល់រាងកាយ និងបញ្ញាស្មារតីជនរងគ្រោះ ដែលបញ្ហាទាំងនេះ ធ្វើឲ្យមានវិបត្តិក្នុងសង្គមកាន់តែធ្ងន់ធ្ងរ ប្រសិនបើមិនមានការទប់ស្កាត់ និងលុបបំបាត់ទាន់ពេលវេលាទេនោះ ។

**សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី និងលោកជំទាវ** ជាទីគោរពដ៏ខ្ពង់ខ្ពស់
ឯកឧត្តម លោកជំទាវ លោកឧកញ៉ា អ្នកឧកញ៉ា លោក លោកស្រី
ក្មួយៗយុវជន និងជនរួមជាតិ ជាទីគោរពស្នេហា

ទិវាជាតិប្រឆាំងការជួញដូរមនុស្ស ត្រូវបានរាជរដ្ឋាភិបាលកម្ពុជា កំណត់យកថ្ងៃ ទី១២ ខែធ្នូ រៀងរាល់ឆ្នាំ តាមលិខិត ទីស្តីការគណៈរដ្ឋមន្ត្រី លេខ ១៧៤៨សជណ.អវ. ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០៧ ដូច្នេះ គិតមកដល់ឆ្នាំ២០១៦នេះ គឺជាឆ្នាំទី១០ហើយ នៃការប្រារព្ធទិវាជាតិនេះ ។

ដោយឡែក នៅឆ្នាំ២០១៥ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សបានរៀបចំប្រារព្ធយ៉ាងអធឹកអធម នៅសាលមហោស្រពកោះពេជ្រនេះ ដោយមានកិត្តិយសដ៏ខ្ពង់ខ្ពស់ ដោយបានការអញ្ជើញចូលរួមផ្តល់កិត្តិយសពីសម្តេច អគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុនរ៉ានី ហ៊ុនសែន** និងបានថ្លែងនូវសារជូនជនរួមជាតិ អំពីការប្តេជ្ញាចិត្តខ្ពស់របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។

ឆ្នាំនេះក៏មិនខុសពីឆ្នាំ២០១៥ដែរ ទិវាជាតិនេះ ត្រូវបានសម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាតំណាងដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងលោកជំទាវ ផ្តល់កិត្តិយសដ៏ខ្ពង់ខ្ពស់ អញ្ជើញជាអធិបតីក្នុងពិធីដ៏មានសារៈសំខាន់នេះ ។ អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីនេះ មានឯកឧត្តម លោកជំទាវ សមាជិករាជរដ្ឋាភិបាល សមាជិករដ្ឋសភា ព្រឹទ្ធសភា ថ្នាក់ដឹកនាំគ្រប់ក្រសួង ស្ថាប័ន អង្គទូតនានាដែលមាននិវេសនដ្ឋាននៅកម្ពុជា ដៃគូអភិវឌ្ឍន៍ជាតិអន្តរជាតិ ផ្នែកឯកជន ផ្នែកសាសនា សកលវិទ្យាល័យ រាជបណ្ឌិត្យសភាកម្ពុជា សាលាបណ្ឌិត្យសភានគរបាលកម្ពុជា សាលាបណ្ឌិត្យសភាវិជ្ជាជីវៈតុលាការ លោកសាស្ត្រាចារ្យ

លោកគ្រូ អ្នកគ្រូ យុវជន សិស្ស និស្សិត សហភាពសហព័ន្ធយុវជន សមាគមនារី យុវជនកាយរឹទ្ធ យុវជនកាកបាទក្រហម កងកម្លាំងគ្រប់ប្រភេទរួមមាន នគរបាល កងរាជអាវុធហត្ថ កងទ័ពជើងទឹក ជើងគោក ជើងអាកាស អាជ្ញាធរដែនដីពីគ្រប់រាជធានី ខេត្ត និងបងប្អូនប្រជាពលរដ្ឋ ដែលជាតំណាង គ្រប់សមាសភាពក្នុងសង្គម សរុបប្រមាណ ៣០០០នាក់ ។

កម្មវិធីនេះ មិនមែនប្រារព្ធតែនៅក្នុងសាលពិធីនេះទេ ប្រជាពលរដ្ឋដែលមិនបានចូលរួមក្នុងទីនេះ ក៏អាចចូលរួមតាមរយៈការផ្សព្វផ្សាយសារ និងសកម្មភាពតាមប្រព័ន្ធ ហ្វេសប៊ុក របស់គណៈកម្មាធិការជាតិ និងហ្វេសប៊ុកឈ្មោះថា «អ្នកក្លាហាន» ដែលមានភ្ជាប់ជាមួយព័ត៌មាន ផ្តល់ការយល់ដឹងមួយចំនួន និងតាមរយៈការផ្សព្វផ្សាយនានាបើកទូលាយឲ្យមានការចូលរួម ទាំងអស់គ្នា ដែលប្រធានបទគន្លឹះក្នុងឆ្នាំនេះគឺ៖ «ពង្រឹងកិច្ចសហការ និងការគ្រប់គ្រងលំហូរទេសន្តរប្រវេសន៍ ដើម្បីប្រសិទ្ធភាពនៃការបង្ការ ទប់ស្កាត់ ការពារ បង្ក្រាប និង ការផ្តន្ទាទោស» ។

កម្មវិធីប្រព្រឹត្តទៅនៅពេលរសៀលនេះ ដោយមានពិធីបង្ហោះប៉េងប៉ោងនាំសារដោយក្រុមយុវជនកាយរឹទ្ធ និងយុវជនកាកបាទក្រហមកម្ពុជា ដោយមានការផ្តល់កិត្តិយសដ៏ខ្ពង់ខ្ពស់ពី**សម្តេចក្រឡាហោម និងលោកជំទាវ** ពេលអញ្ជើញដល់ ដើម្បីចូលរួមបង្ហោះសារទៅគ្រប់ទីកន្លែង ។

នៅក្នុងសាលពិធី នឹងមានរបាយការណ៍សង្ខេប និងបទយកការណ៍ខ្លីមួយ បានបង្ហាញអំពីទិដ្ឋភាពជាក់ស្តែងនៃភាពរងគ្រោះដែលបាន និងកំពុងតែស្ថិតនៅក្រោមរូបភាពចំណាកស្រុកយ៉ាងគគ្រឹកគគ្រេងទាំងស្របច្បាប់ ទាំងមិនស្របច្បាប់ ព្រមទាំងបង្ហាញអំពីប្រតិបត្តិការរបស់គ្រប់សមាសភាពនៃគណៈកម្មាធិការជាតិនៅគ្រប់ថ្នាក់ ក្នុងការបង្ការទប់ស្កាត់ បង្ក្រាប ជួយជនរងគ្រោះ និងកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសនានាដែលពាក់ព័ន្ធ ក្នុងការបង្ការ ទប់ស្កាត់ និងលុបបំបាត់អំពើជួញដូរមនុស្ស ។

បន្ទាប់មក គឺផ្ទាំងទស្សនីយភាពរបាំរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សហការជាមួយក្រុមរបាំសម័យរបស់កញ្ញា ឱក សុគន្ធកញ្ញា ដែលនឹងបង្ហាញនូវទិដ្ឋភាពពាក់ព័ន្ធនឹងការអូសទាញជនរងគ្រោះ និងការរួបរួមគ្នារបស់សហគមន៍ដើម្បីការពារគ្នាទៅវិញទៅមក ព្រមទាំងបញ្ចប់ដោយការបង្ហាញពីភាពសប្បាយរីករាយរបស់ប្រជាពលរដ្ឋក្នុងសហគន៍ ប្រកបដោយទឹកចិត្តស្រឡាញ់ជាតិ មាតុភូមិ ដែលមានវប្បធម៌ដ៏ល្អផូរផង់រួមទាំងបូរាណ និងទំនើប ជាបេះដូងនៃប្រទេសជាតិ ។

នៅទីបញ្ចប់ **សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** នឹងថ្លែងសុន្ទរកថា និងសារដ៏មានសារៈសំខាន់ ជូនជនរួមជាតិ និងសហគមន៍អន្តរជាតិ អំពីការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការប្រយុទ្ធប្រឆាំងដាច់ខាតអំពើជួញដូរមនុស្ស ដោយធានាឲ្យមានកិច្ចសហការគ្នាល្អរវាងក្រសួង ស្ថាប័ន ដៃគូជាតិ និងអន្តរជាតិ និងផ្នែកឯកជន ដើម្បីអនុវត្តសកម្មភាពព្រមៗគ្នា ឆ្ពោះទៅកាន់គោលដៅរួមតែមួយ គឺ **«លុបបំបាត់អំពើជួញដូរមនុស្ស គ្រប់រូបភាព»** ។

ការប្រារព្ធទិវាជាតិប្រឆាំងអំពើជួញដូរមនុស្សនាថ្ងៃនេះ គឺជាយុទ្ធនាការដ៏ធំមួយដើម្បី បំផុសការចូលរួមពីថ្នាក់ដឹកនាំក្នុងរាជរដ្ឋាភិបាល អង្គការសង្គមស៊ីវិល និងផ្នែកឯកជន ក៏ដូចជា បងប្អូនប្រជាពលរដ្ឋគ្រប់រូប ឲ្យមានឆន្ទៈមុតមាំ និងការប្តេជ្ញាចិត្តខ្ពស់ ដើម្បីចូលរួមទាំងអស់គ្នា ដើម្បីបង្ការ

ទប់ស្កាត់ និងការពារប្រជាពលរដ្ឋ និងប្រទេសជាតិយើងឲ្យរស់នៅដោយសុខុដុមរមនា និង «គ្មានអំពើជួញដូរមនុស្ស» ។

នៅក្នុងទិវាជាតិ ដ៏មហាឡារឹកនេះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ ដែលមានក្រសួង អង្គភាពជំនាញ មន្ទីរ ស្ថាប័នជាសមាជិកទាំងអស់ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សូមប្តេជ្ញាចិត្តថា ៖

- ពង្រឹងកិច្ចសហប្រតិបត្តិការរវាងស្ថាប័ននិងដៃគូពាក់ព័ន្ធ ទ្វេភាគី និងពហុភាគី ដោយផ្អែកលើការទទួលខុសត្រូវរួម ដើម្បីដោះស្រាយបញ្ហាដែលនាំឱ្យមានការជួញដូរ កេងប្រវ័ញ្ច និងរំលោភបំពានលើមនុស្សគ្រប់ទម្រង់ ជាពិសេសលើស្ត្រី និងកុមារ
- ពង្រឹងវិធានការគ្រប់គ្រងលំហូរចេញ ចូល តាមព្រំដែនរវាងព្រះរាជាណាចក្រកម្ពុជា និងប្រទេសជិតខាងឲ្យបានល្អ និងរួមគ្នាបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្សគ្រប់រូបភាព
- ការពារសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់ជនរងគ្រោះ ដោយកំណត់អត្តសញ្ញាណឲ្យបានជាក់លាក់ ជៀសវាងការបន្លំ បោកប្រាស់ពីឧក្រិដ្ឋជន ក្នុងគោលដៅបង្វែរបទល្មើស
- ពង្រឹងកិច្ចសហការជាមួយបណ្តាប្រទេសពាក់ព័ន្ធ ក្នុងការស៊ើបអង្កេតបទល្មើស ជួញដូរមនុស្ស ការអនុវត្តច្បាប់ដើម្បីកាត់ទោសលើឧក្រិដ្ឋកម្មជួញដូរមនុស្ស
- ពង្រីកកិច្ចសហប្រតិបត្តិការតំបន់ និងអន្តរជាតិ ជំរុញអនុវត្តកិច្ចព្រមព្រៀង អនុស្សរណៈទ្វេភាគី ពហុភាគី និងផែនការរួមដែលមានស្រាប់ និងកសាងទំនុកចិត្ត និងកិច្ចព្រមព្រៀងជាមួយប្រទេសពាក់ព័ន្ធដទៃទៀត
- ពង្រឹងវិធានការគ្រប់គ្រង ត្រួតពិនិត្យសកម្មភាពជ្រើសរើស បណ្តុះបណ្តាល និងបញ្ជូនពលកររបស់ទីភ្នាក់ងារ ក្រុមហ៊ុនឯកជន និងអង្គការ ឬសមាគម សាលាភាសាបរទេសដែលបាននិងកំពុងតែធ្វើសកម្មភាពយ៉ាងអាណាធិបតេយ្យក្នុងការផ្សព្វផ្សាយទាក់ទាញកម្លាំងយុវជនឲ្យចំណាយក្នុងការចុះឈ្មោះ និងបញ្ជូនទៅក្រៅប្រទេសដោយមិនមានការទទួលខុសត្រូវ ។
- ពង្រឹងការអនុវត្តច្បាប់ ឲ្យរឹតតែម៉ឹងម៉ាត់ ដើម្បីនាំយកជនល្មើសមកផ្តន្ទាទោសតាមទំហំនៃការប្រព្រឹត្ត និងផ្តល់យុត្តិធម៌ជូនជនរងគ្រោះ ។

ក្នុងនាមអគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) ខ្ញុំព្រះករុណាខ្ញុំ សូមគោរពថ្លែងនូវអំណរព្រះគុណ និងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះថ្នាក់ដឹកនាំរាជរដ្ឋាភិបាល និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃក្រសួង-ស្ថាប័នពាក់ព័ន្ធ រាជធានី ខេត្ត អង្គការដៃគូអភិវឌ្ឍន៍ជាតិ និងអន្តរជាតិ និងផ្នែកឯកជនទាំងអស់ ដែលបាននាំគ្នាខិតខំរួមចំណែក ក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា ក្នុងរយៈពេលកន្លងមក រហូតទទួលបានលទ្ធផលគួរឲ្យកត់សម្គាល់ ជាពិសេសការចូលរួមសហការយ៉ាងសកម្ម ដោះស្រាយបញ្ហាចំពោះមុខ ក៏ដូចជាការកំណត់នូវគោលនយោបាយ យុទ្ធសាស្ត្រ និងសកម្មភាពនៅគ្រប់កម្រិតក្នុងការបង្ការ ទប់ស្កាត់ ការការពារជនរងគ្រោះ ការបង្ក្រាប និងការផ្តន្ទាទោសជនល្មើស ។

ជាថ្មីម្តងទៀត ជំនួសមុខអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងគណៈកម្មការរៀបចំទិវាជាតិ នាងខ្ញុំសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះវត្តមានជាអធិបតីដ៏ខ្ពង់ខ្ពស់ របស់ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី តំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា **ព្រមទាំងលោកជំទាវ** និងការចូលរួមដ៏កុះករពីព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ឯកឧត្តម លោកជំទាវ ភ្ញៀវកិត្តិយសជាតិ អន្តរជាតិ អភិបាល អភិបាលរង ក្រុមប្រឹក្សារាជធានី ខេត្ត ខណ្ឌ សង្កាត់ ក្រសួង មន្ទីរស្ថាប័ន គ្រប់ផ្នែកគ្រប់វិស័យ អង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិល ផ្នែកឯកជន ថ្នាក់គ្រប់គ្រងគ្រឹះស្ថានសិក្សា សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ និស្សិត សិស្សានុសិស្ស និងប្រជាពលរដ្ឋ ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ក្នុងការចូលរួមផ្តល់កិត្តិយសក្នុងកម្មវិធីប្រារព្ធទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ ធ្នូ នាថ្ងៃនេះ ។

ជាទីបញ្ចប់ ខ្ញុំព្រះករុណាខ្ញុំសូមប្រគេនពរ និងគោរពជូនពរបវរមហាប្រសើរ ជូនសម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវជាតិ អន្តរជាតិ ក្មួយៗនិស្សិត សិស្សានុសិស្ស និងជនរួមជាតិទាំងអស់ សូមបានប្រកបដោយពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

**សូមអរព្រះគុណ**

**សូមអរគុណ**